ដោះស្រាយវិវាទការងារ

# ព្រឹត្តិប័ត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល

អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងការកាត់សេចក្តី ដោយអាជ្ញាកណ្តាលចងកាតព្វកិច្ច

មិនា ២០១១

## ការដោះស្រាយវិវាទការងារដែលគ្របដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នា

នៅក្នុងខែមិនា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿងចំនួន១៥ ដែលក្នុងនោះមាន១០សំណុំត្រូវគ្រប់ដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នាស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ (MoU) ដែលត្រូវចុះហត្ថលេខា នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ដោយភាគីសហជីព និងនិយោជកដែលពាក់ព័ន្ធនៅក្នុងដំណើរការឧស្សាហកម្មកាត់ដេរសំលៀកបំពាក់។ ក្នុងចំនោមនោះ ភាគីនៃអនុស្សារណៈព្រមព្រៀងទទួលយកការកាត់សេចក្តីដោយអាជ្ញាកណ្តាលចងកាតព្វកិច្ច និងចុងក្រោយចំពោះវាលវិវាទការងារអំពីសិទ្ធិរបស់ពួកគេ។

ជាសរុប ពីខែមករា ដល់មិនា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿងចំនួន ៤៤ ដែលក្នុងនោះមាន ២៦សំណុំរឿងត្រូវបានគ្របដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នា។ តារាងខាងក្រោម បង្ហាញពីចំនួនសំណុំរឿងសរុប ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបាន ដោយបែងចែកជាសំណុំរឿងគ្របដណ្តប់ ដោយ MoU និងសំណុំរឿងមិនគ្របដណ្តប់ដោយ MoU។



# ការសង្កេតលើការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា និងសំណុំរឿងដែលកាត់សេចក្ដីដោយអាជ្ញាកណ្ដាលចងការតព្វកិច្ច

នៅក្នុងខែមិនា ឆ្នាំ២០១១ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានសង្កេតឃើញចំនុចមួយចំនួន ដោយរួមបញ្ចូលទាំងការវិវត្តន៍ជាវិជ្ជមានទាក់ទងនឹងការអនុវត្តអនុស្សារណៈ និងបញ្ហាប្រឈមនៅក្នុងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នានេះ ។

1. ការវិវត្តន៍ជាវិជ្ជមានទាក់ទងនឹងការអនុវត្តអនុស្សារណៈ

មាន១ករណី ភាគីបានឈានដល់កិច្ចព្រមព្រៀងនៅក្នុងសវនាការ ។ វាបានបង្ហាញពីការស្ម័គ្រចិត្តរបស់ភាគីក្នុងការដោះស្រាយវិវាទដោយកិច្ចព្រមព្រៀងដោយខ្លួនរបស់ពួកគេ ។

មិនមានភាគីនៃអនុស្សារណៈណាមួយ អវត្តមាននៅសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ ។ ភាគីនៃអនុស្សារណៈទាំងអស់បានចូលរួមនៅក្នុងគ្រប់ដំណើរការទាំងអស់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។

2. បញ្ហាប្រឈមនៅក្នុងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា

ជាទូទៅ ភាគីមិនមានការរៀបចំបានល្អប្រសើរនៅក្នុងការបង្ហាញភស្តុតាងមកដល់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅពេលសវនាការនោះទេ ។ ពោលគឺភាគី បានបន្តផ្ដល់ភស្តុតាងបន្ទាប់ពីសវនាការ ជំនួសឱ្យការផ្ដល់ភស្តុតាងកំឡុងពេល ឬក៏មុនសវនាការ ។

មាន១ករណី សហជីពដែលជាហត្ថលេខី នៅក្នុងអនុស្សារណៈ បានបន្តធ្វើកូដកម្មនៅមុនថ្ងៃសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបង្គាប់បណ្ដោះអាសន្ន ដើម្បីហៅកម្មករនិយោជិកត្រលប់មកធ្វើការវិញ ។ កម្មករនិយោជិកបានត្រលប់មកធ្វើការវិញ ហើយក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏បានបន្តនិតិវិធីរបស់ខ្លួន ។

មាន១ករណី មេធាវីខាងនិយោជកមិនបានយល់ដឹងអំពីអនុស្សារណៈនៃការយោគយល់នោះទេ ហើយគាត់បានមានប្រសាសន៍ថាអនុស្សារណៈនេះមិនអនុលោមទៅតាមច្បាប់ទេ ដោយសារវាមិនអនុញ្ញាតឱ្យភាគីបដិសេធវិវាទអំពីសិទ្ធិ ។ ទោះជាយ៉ាងនេះក្ដី មេធាវី នោះបានចុះហត្ថលេខាដាច់ដោយឡែកដើម្បីទទួលយកសេចក្ដីបង្គាប់ជាប់កាតព្វកិច្ចចំពោះវិវាទអំពីសិទ្ធិ ។

មាន១ករណី ភាគីនិយោជកបានដាក់លិខិតជំទាស់មកក្រុមប្រឹក្សាអាជ្ញាកណ្ដាល ប្រឆាំងនឹងការសម្រេចចិត្ត លើវិវាទអំពីសិទ្ធិ បើទោះជាខាងនិយោជកគឺជាភាគីនៃអនុស្សារណៈក៏ដោយ ។



មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្តល់បទបញ្ជាផ្ទៃក្នុងរបស់សវនាការដល់ភាគី

+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=
អ្នកត្រូវបានជ្រើសរើសដើម្បីទទួលនូវអ៊ីម៉ែលនេះពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល
ដើម្បីឈប់ទទួលព្រឹត្តិប័ត្រអេឡិចត្រូនិចនេះ សូមអ៊ីម៉ែលទៅ
dvandeth@arbitrationcouncil.org ជាមួយប្រធានបទ“Unsubscribe – The AC E-Newsletter”.

អ្នកត្រូវបានជ្រើសរើសដើម្បីទទួលនូវអ៊ីម៉ែលនេះពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល
ដើម្បីទទួលព្រឹត្តិប័ត្រអេឡិចត្រូនិចនេះ សូមអ៊ីម៉ែលទៅ
dvandeth@arbitrationcouncil.org ជាមួយប្រធានបទ “Subscribe – The AC E-Newsletter”.
+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=+=

ផ្ទះលេខ៧២ ផ្លូវ៥៩២ កែង ផ្លូវលេខ៣២៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក
ទូរសព្ទ: ៨៥៥ ២៣ ៨៨១ ៨១៤
ទូរសារ: ៨៥៥ ២៣ ៨៨១ ៩១៨
អ៊ីម៉ែល info@arbitrationcouncil.org
វែបសាយ www.arbitrationcouncil.org